ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៥១៣.០២៣.១០១.ស.ជ.ណ

*ថ្ងៃសុក្រ ១៣កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣*

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការផ្លាស់ប្ដូរគេហទំព័រផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាសូមជម្រាបជូន សាធារណជន មេត្តាជ្រាបថា ដើម្បីពង្រឹងសុវត្ថិភាពក្នុងការគ្រប់គ្រងនិងប្រើប្រាស់គេហទំព័រផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ក៏ដូចជាឱ្យមានសង្គតិភាពជាមួយរាជរដ្ឋាភិបាលក្នុងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងបណ្ដាញសកល (ប្រព័ន្ធអ៊ីនធឺណែត) ធនាគារជាតិនៃកម្ពុជាបានធ្វើការផ្លាស់ប្ដូរគេហទំព័រផ្លូវការពី www.nbc.org.kh ទៅជា www.nbc.gov.kh ដែលគេហទំព័រថ្មីនេះអាចប្រើប្រាស់បានចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។ ទន្ទឹមនេះ សាធារណជនអាចស្វែងរក ព័ត៌មាន ទិន្នន័យ និងឯកសារច្បាប់និងបទប្បញ្ញត្តិដែលស្ថិតក្រោមសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជានៅក្នុងគេហទំព័រថ្មីនេះ ដូចគ្នាទៅនឹងគេហទំព័រចាស់។ គួរបញ្ជាក់ថា គេហទំព័រចាស់មានសុពលភាពប្រើប្រាស់បានរហូតដល់ដំណាច់ឆ្នាំ២០២៣។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh

**បណ្ដាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA